**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៧ អនក្រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញតម្រូវការចាំបាច់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**សម្រេច**

**ប្រការ១:** បង្កើតក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅៈ

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **នាង** | **ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ប្រធាន |
| ២- | ឯកឧត្តម | **សុខ** | **ខាន់ន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៣- | ឯកឧត្តម | **ស៊ា** | **ម៉ៅ** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងជា សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | ឯកឧត្តម | **កៅ** | **ឆារ៉ូ** | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម | **ជៀម** | **សួរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦- | ឯកឧត្តម | **ហាក់** | **សុខហេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការ គណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | លោក | **ជា** | **សុជាតិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |

www.pheakdeylaw.com

| | | | | | |
|---|---|---|---|---|---|
| ៨- | លោក | **ហួយ** | **ឌុន្លា** | ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩- | លោកស្រី | **យ៉ែម** | **ភាន់នីភា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០- | លោក | **កែវ** | **ចិសិដ្ឋ** | អធិការ នៃអគ្គាធិការដ្ឋាន ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១- | វីរសេនីយ៍ឯក | **វ៉ាន់** | **លីហៀង** | ជំនួយការឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | សមាជិក |
| ១២- | លោក | **ប៉ាងប៉ុន** | **តុលា** | ប្រធានការិយាល័យសម្របសម្រួល និងដោះស្រាយវិវាទ នៃនាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |

**ប្រការ២:** ក្រុមការងារអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មានភារកិច្ចដូចតទៅៈ

(ក)- ពិភាក្សា និងសិក្សានូវរាល់គំរូស្តីពីការអភិវឌ្ឍរួមគ្នា របស់បណ្តាប្រទេសមួយចំនួន ដែលបានអនុវត្តប្រកបដោយជោគជ័យ។

(ខ)- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ក្នុងករណីចាំបាច់។

(គ)- ធ្វើសេចក្តីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ជូនអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ (Sub-JTC) និងគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ (JTC) ដើម្បីជាមូលដ្ឋានក្នុងការពិចារណា និងលើកសំណើជូនថ្នាក់ដឹកនាំកំពូលពិនិត្យ សម្រេច។

**ប្រការ៣:** គ្រប់សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន។

**ប្រការ៤:** ក្រុមការងារមានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥:** ក្រុមការងារមានសិទ្ធិប្រើប្រាស់មូលនិធិ ដែលជាចំណូលពីវិស័យប្រេងកាតនៃក្រសួងរ៉ែ និងថាមពល តាមរយៈ JTC និង Sub-JTC សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ៦:** សេចក្តីសម្រេចលេខ ១៧ សសរ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ និង ខ្លឹមសារទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧:** ប្រធាន និងសមាជិកក្រុមការងារ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com